ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ
# អភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា
# ២០១៦-២០២៥

ឆ្នាំ ២០១៦

សហការ និងឧបត្ថមការបោះពុម្ពដោយ កម្មវិធីឡជីវឧស្ម័នជាតិ

និង រដ្ឋាភិបាលប្រទេសឆេកូ តាមរយៈអង្គការភីន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ម.ព.ឯ.ក AIDOC
Code: 246-006
Date:
Donated by:

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ
# អភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា
# ឆ្នាំ២០១៦-២០២៥

ឆ្នាំ២០១៦

៥

# គោលនយោបាយ
# អភិវឌ្ឍន៍ឡជីវខុស្ស័នទៅកម្ពុជាឆ្នាំ២០១៦-២០២៥

## ១. សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ហើយនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដោយបានកំណត់យ៉ាងច្បាស់ថា ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ការកែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ពិសេសធនធានព្រៃឈើនិងជលផល គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ទិសដៅគោលនយោបាយរួមក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម គឺសំដៅជំរុញកំណើនកសិកម្មឱ្យបានក្នុងរង្វង់៥%ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព។

អនុវត្តតាមគោលនយោបាយនិងយុទ្ធសាស្ត្រនេះ វិធានការចាំបាច់មួយចំនួនត្រូវបានដាក់ឱ្យអនុវត្តរួមមាន ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនការផ្ដល់សេវាបច្ចេកទេសកសិកម្មដល់កសិករ ពង្រឹងការស្រាវជ្រាវបច្ចេកទេសកសិកម្ម សំដៅបង្កើនផលិតភាពដំណាំនិងសត្វ និងបន្សាំការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនជីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម និងការកសាងនិងពង្រឹងសមត្ថភាពស្ថាប័នដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម។

ទន្ទឹមនឹងនេះ ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ត្រូវបានផ្ដល់អាទិភាពខ្ពស់ក្នុងកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម។ ការអនុវត្តច្បាប់ស្ដីពីសុខភាពសត្វនិងផលិតកម្មសត្វ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ២០១៦-២០២៥ និងវិធានការបច្ចេកទេសចាំបាច់នានាក្នុងផលិតកម្មសត្វ គឺជាលក្ខខណ្ឌតម្រូវដើម្បីធានាចីរភាពនិងការអភិវឌ្ឍបៃតង។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតកម្មសត្វ បង្កើនប្រាក់ចំណូលជូនប្រជាកសិករចិញ្ចឹមសត្វ។

កម្មវិធីជំរុញផលិតកម្មសត្វនិងសុខភាពសត្វត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងគោលដៅជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវ និងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វនិងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់សត្វសាច់សត្វ ប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្ដានុភាពនៃការនាំចេញ។

ផលិតកម្មសត្វត្រូវបានសង្កេតឃើញថា មានការវិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់នាពេលកន្លងមក។ ជាមួយគ្នានេះ ការគ្រប់គ្រងកាកសំណល់ពីផលិតកម្មសត្វ ពិសេសការគ្រប់គ្រងលាមកសត្វ និងកាកសំណល់សត្តឃាតដ្ឋាន ត្រូវបានទទួលការយកចិត្តខ្ពស់ ដើម្បីធានាបាននូវបរិស្ថានស្អាត និងរួមចំណែកក្នុងការអភិវឌ្ឍបៃតង។ ការសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន ផ្សារភ្ជាប់នឹងការបង្កើតប្រព័ន្ធកសិកម្មចម្រុះ គឺជាវិធានការចាំបាច់មួយដែលអាចដោះស្រាយបាននូវបញ្ហាគ្រប់គ្រងកាកសំណល់សត្វ និងការបង្កើនផលិតភាពសត្វ។ សហគមន៍ប្រើប្រាស់ឡជីវឧស្ម័ន ក៏ជាយន្តការសំខាន់មួយទៀតដែលត្រូវបង្កើត និងពង្រីកនៅទូទាំងប្រទេស។

ក្នុងគោលបំណងជំរុញការបង្កើតនិងប្រើប្រាស់ឡជីវឧស្ម័នឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥ សម្រាប់ដាក់ឱ្យអនុវត្តនាពេលខាងមុខ។ គោលនយោបាយនេះ នឹងបង្ហាញនូវគោលបំណង និងគោលដៅច្បាស់លាស់ ពិសេសការរៀបចំយុទ្ធសាស្ត្រជាក់លាក់ សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា។

## ១.១ ស្ថានភាពផលិតកម្មសត្វ

ផលិតកម្មសត្វជាលក្ខណៈគ្រួសារ និងជាលក្ខណៈពាណិជ្ជកម្មនៅកម្ពុជា ជាពិសេស ការចិញ្ចឹមសត្វជ្រូកនិងបក្សី មានការវិវឌ្ឍរីកចម្រើនគួរឲ្យកត់សម្គាល់ ដែលផលិតកម្មនេះអាចធានាការផ្គត់ផ្គង់សេចក្ដីត្រូវការក្នុងស្រុកនាពេលកន្លងមក ហើយមានសត្វនិងផលិតផលមានដើមកំណើតពីសត្វមួយចំនួនត្រូវបាននាំចេញទៅបរទេស។ ផលិតកម្មសត្វគោជាលក្ខណៈគ្រួសារក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១១ដល់ឆ្នាំ២០១៥នេះ មានការប្រែប្រួលថយចុះប្រមាណ៣,៤៩% ដោយបានថយចុះពី៣,៤លានក្បាលនាឆ្នាំ២០១១ មកត្រឹម២,៩លានក្បាលនាឆ្នាំ២០១៥។ រីឯក្របីក៏មានការប្រែប្រួលថយចុះប្រមាណ៦,២៧% គឺបានថយចុះពីចំនួន៦៨៩.៨២៩ក្បាលនាឆ្នាំ២០១១ មកត្រឹមតែ៥០៦.១៦៥ក្បាលនាឆ្នាំ២០១៥។ ការថយចុះចំពោះផលិតកម្មចិញ្ចឹមសត្វគោក្របីជាលក្ខណៈគ្រួសារនេះ គឺជាការថយចុះគោក្របីអូសទាញ មូលហេតុបណ្ដាលមកពីកសិករកាន់តែច្រើនឡើងៗ បានបោះបង់ការភ្ជួររាស់ដោយគោក្របី មកប្រើប្រាស់សេវាគ្រឿងយន្ត

កសិកម្មជំនួសវិញ (ប្រហែល៨៤%នៃផ្ទៃដីដាំដុះដំណាំស្រូវត្រូវបានអនុវត្តដោយគ្រឿងយន្តកសិកម្ម) និងកង្វះកម្លាំងពលកម្មនៅជនបទ (ចំណាកស្រុក)។ ទន្ទឹមនឹងការថយចុះគោក្របីអូសទាញនេះ កសិករបានងាកមកចិញ្ចឹមគោមេនិងគោយកសាច់ និងជាមួយគ្នានោះ ក៏មានការចាប់ផ្ដើមការវិនិយោគឯកជនចិញ្ចឹមគោសាច់វិញផងដែរ។

ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារមានការប្រែប្រួលកើនឡើង ក្នុងអំឡុងពេល៥ឆ្នាំកន្លងទៅនេះ ពោលគឺផលិតកម្មជ្រូកបានកើនប្រមាណ២,៨៧% ដោយបានកើនឡើងពី២,០៩លានក្បាលនាឆ្នាំ២០១១ ដល់ចំនួនជាង២,៣៥លានក្បាលនាឆ្នាំ២០១៥។ ចំណែកផលិតកម្មចំណីសត្វ មានការវិនិយោគបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក។ បន្ថែមពីនេះទៀត ប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិតដំណាំចំណីសត្វ និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចយ៉ាងផុលផុស។ ទោះជាយ៉ាងនេះក្ដី ចំណីនិងថ្នាំព្យាបាលសត្វនៅមានតម្លៃខ្ពស់នៅឡើយ។

ការចិញ្ចឹមបក្សី (មាន់ ទា) មានការកើនឡើងយ៉ាងខ្លាំង ក្នុងនោះការចិញ្ចឹមជាលក្ខណៈគ្រួសារអំឡុងពេល៥ឆ្នាំ (ឆ្នាំ២០១១ដល់២០១៥) បានកើនឡើងប្រមាណ៥,៣៩% គឺកើនពីជាង២២លានក្បាលនាឆ្នាំ២០១១ ដល់ជាង២៦,៥០លានក្បាលនាឆ្នាំ២០១៥។ នេះបញ្ជាក់ឲ្យឃើញថា ប្រជាកសិករមានការយល់ដឹងបណ្ដើរៗនូវបច្ចេកទេសចិញ្ចឹមសត្វតាមគោលការណ៍ជីវសុវត្ថិភាព និងការយល់ដឹងអំពីវិធានការទប់ស្កាត់ជំងឺឆ្លង។ ការបង្ការការពារសុវត្ថិភាពមនុស្សសត្វក៏ត្រូវបានអនុវត្ត និងទទួលបានលទ្ធផលល្អប្រសើរ ដោយអត្រាឈឺស្លាប់សត្វមានកម្រិតទាប។ ជំងឺផ្ដាសាយបក្សីត្រូវបានទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព។ ការត្រួតពិនិត្យអនាម័យសត្វ ផលិតផលសត្វត្រូវបានយកចិត្តទុកដាក់ ដោយអនុវត្តចាប់ផ្ដើមពីកសិដ្ឋាន កន្លែងពិឃាដដល់ទីផ្សារ ជាពិសេសការត្រួតពិនិត្យអនាម័យក្នុងការនាំចេញ នាំចូល នាំឆ្លងកាត់សត្វ និងផលិតផលមានដើមកំណើតពីសត្វ។

លើសពីនេះទៀត ការចិញ្ចឹមសត្វបែបលក្ខណៈពាណិជ្ជកម្ម ក៏មានសកម្មភាពរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។ កសិដ្ឋានចិញ្ចឹមសត្វគោ ជ្រូក មាន់ទា ធុនតូចមធ្យមនិងធំត្រូវបានអភិវឌ្ឍន៍ និងមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ បរិមាណសត្វគោដែលបានចិញ្ចឹមក្នុងកសិដ្ឋាន បានកើនឡើងពី ៤.៧៧០ ក្បាល នៅឆ្នាំ២០១១ ដល់ប្រមាណ ១៣.០០០ក្បាល នៅឆ្នាំ២០១៥ (កើន៣២% ប្រៀបធៀបរយៈពេល៥ឆ្នាំ)។ ផលិតកម្មចិញ្ចឹមជ្រូកបានកើនពី១៦៤ពាន់ក្បាល ឆ្នាំ២០១១ ដល់ជាង៤១៦ពាន់ក្បាលនៅឆ្នាំ២០១៥ កើន២៣% ប្រៀបធៀបរយៈពេល៥ឆ្នាំ)។ ដោយឡែក ចំពោះការចិញ្ចឹមមាន់ទាក្នុងកសិដ្ឋានបានកើនឡើង

ពី១,៧៧លានក្បាល នៅឆ្នាំ២០១១ ដល់ប្រមាណជាង៣លានក្បាល នៅឆ្នាំ២០១៥ (កើន ២៣,៣៥% ប្រៀបធៀបរយៈពេល៥ឆ្នាំ)។

ទន្ទឹមនឹងនោះ កម្ពុជាត្រូវបន្តធ្វើការងារជាច្រើន ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តជាអន្តរជាតិ ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការអនុវត្តបទដ្ឋានអនាម័យសម្រាប់ផលិតផលសត្វ និងពង្រឹងការអនុវត្តវិធានការអនាម័យសត្វ ក្នុងគោលដៅការពារនិងប្រយុទ្ធប្រឆាំងជំងឺឆ្លង ការពារសុខភាពសាធារណៈ តាមរយៈការការពារជំងឺឆ្លងពីសត្វទៅមនុស្សនិងពីមនុស្សទៅសត្វ និងបង្កើតសត្តឃាតដ្ឋានទំនើប ដើម្បីធានាសុខភាពសាធារណៈ និងជួយសម្រួលពាណិជ្ជកម្ម។

ចំពោះការកែលម្អពូជ គឺកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរផងដែរ ព្រោះប្រជាកសិករភាគច្រើន កាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វ ជាកត្តាសំខាន់ដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ ហើយនឹងបានផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។ ជាមួយគ្នានោះ ការផ្សព្វផ្សាយបច្ចេកទេសក្នុងជួរកសិករត្រូវបានអនុវត្តយ៉ាងសកម្មនិងមានប្រសិទ្ធភាព ដែលជាលទ្ធផលចំនួនបក្សីមានការកើនឡើង និងធានាបាននូវការផ្គត់ផ្គង់សាច់ ស៊ុត នៅក្នុងប្រទេស ហើយកសិដ្ឋានផលិតកម្មមានលក្ខណៈពាណិជ្ជកម្ម កំពុងរីកចម្រើនជាបណ្តើរៗហើយដែរ។

នេះបញ្ជាក់ថា ប្រទេសកម្ពុជាមានលទ្ធភាពជំរុញ និងពង្រីកផលិតកម្មសត្វបន្ថែមទៀត តាមរយៈ (ទី១) ការកាត់បន្ថយហានិភ័យនិងការផ្ទុះជំងឺសត្វ (ទី២) ការអភិវឌ្ឍសមត្ថភាពកសិករ ភ្នាក់ងារសុខភាពសត្វភូមិ និងអ្នកពាក់ព័ន្ធក្នុងការអនុវត្តការចិញ្ចឹមសត្វល្អ ជីវសុវត្ថិភាព និងការត្រួតពិនិត្យជំងឺសត្វ (ទី៣) បង្កើនប្រាក់ចំណូលកសិករ តាមរយៈការអភិវឌ្ឍផលិតកម្មសត្វ និង (ទី៤) គាំទ្រឧស្សាហកម្មសត្វ ចំណីសត្វ និងបសុឱសថ ដើម្បីឆ្លើយតបនឹងតម្រូវការកើនឡើងម្ហូបអាហារនៅក្នុងប្រទេសកម្ពុជា និងសម្រាប់នាំចេញ។

ដោយមានការអភិវឌ្ឍវិស័យចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វ ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ តាមរយៈការអប់រំណែនាំ ផ្សព្វផ្សាយការអនុវត្តល្អប្រសើរលើការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។

## ១.២ ការចិញ្ចឹមសត្វទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

ការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្របានបង្ហាញថា សត្វបានរួមចំណែកប្រមាណ១៨%នៃការបំភាយឧស្ម័នផ្ទះកញ្ចក់នៅលើពិភពលោក (របាយការណ៍ប្រចាំឆ្នាំ២០០៨-២០០៩ របស់វិទ្យាស្ថានស្រាវជ្រាវសត្វ

អន្តរជាតិ - ILRI Report 2008-2009)។ ឧស្ម័នផ្ទះកញ្ចក់ដែលបំភាយពីប្រព័ន្ធផលិតកម្មសត្វរួមមាន÷ (១)ឧស្ម័នមេតានដែលផលិតដោយសត្វមានប្រមាណ២៥% (២)ឧស្ម័នកាបូនិកដែលភាយចេញពីការប្រើប្រាស់ដីតាមរយៈការបំលែងសារធាតុសរីរាង្គ និងកាកសំណល់សត្វចំនួនប្រហែល៣២% និងអាសូតម៉ូណូអុកស៊ីតដែលភាយចេញពីកាកសំណល់សត្វចំនួន៣១%។

កត្តាដែលរួមចំណែកក្នុងការបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលផលិតដោយប្រព័ន្ធផលិតកម្មសត្វនៅលើពិភពលោក រួមមាន÷ ការពង្រីកការអភិវឌ្ឍការចិញ្ចឹមសត្វយ៉ាងលឿន និងការប្រើប្រាស់ដីព្រៃ ដើម្បីពង្រីកវាលស្មៅ និងផលិតកម្មដំណាំចំណីសត្វ។ ដោយឡែកនៅប្រទេសកម្ពុជា តាមរយៈទិន្នន័យក្រសួងបរិស្ថាននៅឆ្នាំ២០០០ បានបង្ហាញថា ការបំភាយឧស្ម័នមេតានពីការធ្វើលឿងក្នុងក្រពះសត្វ (Fermentation) មានចំនួន១៦៣,៨២Gg[1] (ស្មើ៣៤៤០,៣១Gg នៃឧស្ម័នកាបូនិកសរុបពីវិស័យកសិកម្ម) និងការបំភាយឧស្ម័នមេតានមានចំនួន២២,៣៧Gg និងអាសូតម៉ូណូអុកស៊ីតមានចំនួន១,១១Gg ពីលាមកសត្វ (ស្មើ៨១២,៩០Gg នៃឧស្ម័នកាបូនិកសរុបពីវិស័យកសិកម្ម) ដែលការបំភាយនេះគឺមានចំនួន៤២៥៣,២១Gg (ស្មើនឹង២០%) នៃការបំភាយឧស្ម័នកាបូនិកពីវិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជា។

ការកើនកម្តៅនឹងកាត់បន្ថយកម្រិតរលាយនៃប្រភេទរុក្ខជាតិ ដែលនាំឲ្យកាត់បន្ថយសារធាតុចិញ្ចឹមរបស់ដំណាំចំណីសត្វ។ ការកើនកម្តៅនឹងធ្វើឲ្យប្រែប្រួលការផ្លាស់ប្តូរកម្តៅរវាងសត្វនិងបរិស្ថាន ជាពិសេសស្រ្តេសកម្តៅនឹងធ្វើឲ្យប៉ះពាល់ដល់ការស៊ីចំណី ការលូតលាស់ ការបន្តពូជ ការទ្រទ្រង់រាងកាយនិងអាយុកាលរបស់សត្វ។ ទោះបីជាយ៉ាងណាក៏ដោយ ការជះឥទ្ធិពលរបស់សត្វដោយសារស្រ្តេសកម្តៅ គឺមានការប្រែប្រួលអាស្រ័យនឹងប្រភេទសត្វនិងកត្តាផ្សេងទៀត។

ការប្រែប្រួលអាកាសធាតុ អាចធ្វើឲ្យប្រែប្រួលករណីផ្ទុះជំងឺ និងរបាយនៃជំងឺឆ្លងសត្វតាមមធ្យោបាយជាច្រើន។ ការកើនកម្តៅ ភាពរាំងស្ងួត និងទឹកជំនន់ នឹងធ្វើឲ្យប៉ះពាល់ដល់ចំនួនមេរោគបង្កជំងឺ ការឆ្លើយតបភាពស៊ាំរបស់សត្វទៅនឹងជំងឺ ភ្នាក់ងារចម្លងជំងឺ និងការរីករាលដាលជំងឺ។ ការកើនសីតុណ្ហភាព២,៥អង្សាសេនៅលើពិភពលោក អាចបង្កឲ្យមានការបាត់បង់ជីវចម្រុះ ហើយត្រូវបានគេវាយតម្លៃថាប្រមាណ២០ទៅ៣០%នៃប្រភេទរុក្ខជាតិនិងសត្វ នឹងស្ថិតក្នុងភាពគ្រោះថ្នាក់ផុតពូជនៅពេលកើនសីតុណ្ហភាពនេះ។

---

[1] ១០⁶g= ១ Gg= ១kt (១ គីឡូតោន)

ភាពរកបាននៃចំណីសត្វ ត្រូវបានប៉ះពាល់យ៉ាងខ្លាំងពីការប្រែប្រួលអាកាសធាតុ និងអាចបង្កឱ្យមានបញ្ហាយ៉ាងខ្លាំងដល់វិស័យផលិតកម្មសត្វទាំងមូល និងប្រព័ន្ធផលិតកម្មសត្វពិសេសណាមួយ។ ក្នុងប្រព័ន្ធផលិតកម្មដែលអាស្រ័យដោយដី ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ បាននាំឲ្យមានបញ្ហាបន្ថែមទៀតលើបញ្ហាដែលមានស្រាប់ ដូចជាភាពគ្មាននិរន្តរភាពនៃវាលស្មៅ និងដំណាំចំណីសត្វ ការប្រើប្រាស់ទឹក ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធអេកូឡូស៊ីដីសម្រាប់ចិញ្ចឹមសត្វ ដែលកត្តាទាំងអស់នេះបានប៉ះពាល់ដល់ភាពរកបាននៃចំណីសត្វ។

## ១.៣ ស្ថានភាពនៃការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា

ជាការកត់សម្គាល់គឺប្រជាកសិករមានតម្រូវការប្រើប្រាស់ថាមពលច្រើនសម្រាប់ចម្អិនអាហារ និងការបំភ្លឺក្នុងគ្រួសារ (ប្រមាណ៨៣,៦%នៃគ្រួសារកសិករ ប្រើប្រាស់អុស ចម្អិនអាហារ និង៧,៥%ប្រើប្រាស់ធ្យូងចំអិនអាហារ)។ បច្ចុប្បន្ននេះ កសិករ ម្ចាស់ឡជីវឧស្ម័នជាង៩៥% បានប្រើប្រាស់ជីធម្មជាតិ និងកំពុងត្រូវការជីធម្មជាតិនេះបន្ថែមទៀត ហើយកាកសំណល់រឹងរាវចេញពីឡជីវឧស្ម័ន ជាប្រភពជីធម្មជាតិដ៏ពេញនិយមរបស់កសិករ។

កម្មវិធីឡជីវឧស្ម័នជាតិគឺជាកម្មវិធីមួយ មានការគាំទ្រពីអង្គការអភិវឌ្ឍន៍ប្រទេសហូឡង់ (SNV) ដែលត្រូវបានគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសម្របសម្រួលអនុវត្តដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល។ កម្មវិធីនេះ ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០០៦ រហូតដល់បច្ចុប្បន្ននេះ ដែលអាចជួយទប់ស្កាត់ការបន្ថយឧស្ម័នផ្ទះកញ្ចក់ពីផលិតកម្មសត្វទៅក្នុងបរិស្ថាន តាមរយៈការសាងសង់ឡជីវឧស្ម័ន ហើយត្រូវបានទទួលការគាំទ្រពីប្រជាកសិករ អ្នកចិញ្ចឹមសត្វតាមកសិដ្ឋានធំៗ និងអ្នកពាក់ព័ន្ធផ្សេងទៀត ព្រមទាំងបានរួមចំណែកបង្កើនប្រាក់ចំណូលក្នុងគ្រួសាររបស់កសិករ និងជួយការពារបរិស្ថាន។

ជាលទ្ធផល មកទល់ពេលនេះ ឡជីវឧស្ម័នចំនួនជាង២៥ពាន់[2] ត្រូវបានសាងសង់ឡើងក្រោមកម្មវិធីឡជីវឧស្ម័នជាតិ និងជាង៩០%នៃចំនួនឡជីវឧស្ម័ននៅបន្តនិរន្តរភាព។ ក្នុងការអនុវត្តកម្មវិធីឡជីវឧស្ម័នជាតិមានប្រជាកសិករប្រមាណជាង១៣០ពាន់គ្រួសារ បានទទួលផលដោយផ្ទាល់ពីកម្មវិធីនេះ។ ជាការកត់សម្គាល់មួយទៀត គ្រួសារកសិករចំនួនប្រហែល៣.៥០០គ្រួសារ (១៥%នៃគ្រួសារកសិករសាងសង់ឡជីវឧស្ម័ន) បាន

[2] សក្តានុពលសាងសង់ឡជីវឧស្ម័ននៅប្រទេសកម្ពុជាមានប្រមាណជិត១លានគ្រួសារ ( មានលាមកសត្វចាប់ពី ១០ kg ឡើងទៅ)

ភ្ជាប់បង្គន់អនាម័យជាមួយឡជីវឧស្ម័ន។ លើសពីនេះទៀត ភ្នាក់ងារសាងសង់ឡជីវឧស្ម័នចំនួនប្រមាណ៥៨ ក្រុមត្រូវបានបង្កើតឡើង សម្រាប់ចូលរួមក្នុងការសាងសង់ឡជីវឧស្ម័នដល់កសិករ ដែលមានតម្រូវការ។

ជាលទ្ធផលក្នុងការអនុវត្តកម្មវិធីឡជីវឧស្ម័នជាតិ ការប្រើប្រាស់ឡជីវឧស្ម័នបានធ្វើឱ្យកសិករអាចសន្សំការប្រើប្រាស់អុសធ្យូងបានប្រមាណ២តោនក្នុងមួយឆ្នាំក្នុងមួយឡ ហើយឡជីវឧស្ម័ននេះក៏បានរួមចំណែកក្នុងការកាត់បន្ថយការបំភាយឧស្ម័នកាបូនិក ពីផលិតកម្មសត្វប្រមាណ៤,៥តោនក្នុងមួយឡក្នុងមួយឆ្នាំផងដែរ។

តារាងទី១÷ តម្លៃសាងសង់ឡជីវឧស្ម័ន[3] នៅកម្ពុជា

| ទំហំឡ (ម៉ែត្រគូប) | តម្លៃសាងសង់ (ដុល្លារអាមេរិក) | ប្រាក់ឧបត្ថម្ភពីកម្មវិធីឡជីវឧស្ម័ន (ដុល្លារអាមេរិក) | ចំណាយរបស់កសិករ (ដុល្លារអាមេរិក) | រយៈពេលប្រើប្រាស់សម្រាប់ចង្ក្រានមួយ (ម៉ោង) | រយៈពេលប្រើប្រាស់សម្រាប់អំពូលភ្លើងមួយ (ម៉ោង) |
|---|---|---|---|---|---|
| ២ | ៣០៤ | ១៥០ | ១៥៤ | ១-២ | ៤-៨ |
| ៣ | ៣៨១ | ១៥០ | ២៣១ | ២-៣ | ៨-១២ |
| ៤ | ៤៩០ | ១៥០ | ៣៤០ | ២-៤ | ៨-១៦ |
| ៦ | ៥៥០ | ១៥០ | ៤០០ | ៤-៦ | ១៦-២៤ |
| ៨ | ៧២០ | ១៥០ | ៥៧០ | ៦-៨ | ២៤-៣២ |
| ១០ | ៨១០ | ១៥០ | ៦៦០ | ៨-១០ | ៣២-៤០ |
| ១៥ | ១.១០០ | ១៥០ | ៩៥០ | ១០-១៥ | ៤០-៦០ |

*ប្រភព÷ កម្មវិធីឡជីវឧស្ម័នជាតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

## ១.៤ កាលានុវត្តភាព និងបញ្ហាប្រឈម ក្នុងការអភិវឌ្ឍឡជីវឧស្ម័ន

### ក. កាលានុវត្តភាព

- ការចិញ្ចឹមសត្វមានការរីកចម្រើន ទាំងក្នុងស្រទាប់ប្រជាកសិករ និងទាំងក្នុងក្របខ័ណ្ឌកសិដ្ឋានខ្នាតតូច មធ្យម និងធំ ដែលជាប្រភពផ្តល់កាកសំណល់សត្វ សម្រាប់ប្រើប្រាស់ក្នុងឡជីវឧស្ម័ន
- ការកើនឡើងនូវសត្តឃាតដ្ឋាន ក៏ជាប្រភពផ្តល់កាកសំណល់បន្ថែមមួយទៀត សម្រាប់ប្រើប្រាស់ក្នុងឡជីវឧស្ម័នផងដែរ

[3] អាយុកាលឡជីវឧស្ម័នប្រើបានជាង២០ឆ្នាំ

- និន្នាការប្រើប្រាស់ឡជីវឧស្ម័នរបស់ប្រជាកសិករនៅតាមតំបន់ជនបទ ត្រូវបានសង្កេតឃើញថាមានការកើនឡើងគួរឱ្យកត់សម្គាល់
- មានការគាំទ្រយ៉ាងពេញទំហឹងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើផ្នែកបច្ចេកទេស ពិសេសការជំរុញឱ្យអនុវត្តកម្មវិធីឡជីវឧស្ម័នជាតិ
- គោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម បានផ្តោតលើការគ្រប់គ្រងកាកសំណល់ប្រកបដោយប្រសិទ្ធភាព ដោយជំរុញឱ្យមានការរៀបចំសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន
- បណ្តាដៃគូអភិវឌ្ឍន៍នានា បានយកចិត្តទុកដាក់ដល់ការអនុវត្តកម្មវិធីឡជីវឧស្ម័នជាតិ និងបានបង្កើនធនធានទាំងផ្នែកបច្ចេកទេស ក៏ដូចជាធនធានថវិកា សម្រាប់ដំណើរការអនុវត្តនាពេលកន្លងមក។

### ខ. បញ្ហាប្រឈម

- ការយល់ដឹងពីបច្ចេកទេសសាងសង់ និងការប្រើប្រាស់ឡជីវឧស្ម័នរបស់ប្រជាកសិករ នៅមានកម្រិតនៅឡើយ ពិសេសកសិករនៅតាមតំបន់ជនបទដាច់ស្រយាល
- បច្ចេកទេសសាងសង់ឡជីវឧស្ម័ន និងការស្រាវជ្រាវបច្ចេកវិទ្យា រួមនឹងការងារផ្សព្វផ្សាយ ការអភិវឌ្ឍ និងប្រើប្រាស់ឡជីវឧស្ម័ននៅមានកម្រិត
- ការពឹងផ្អែកលើការប្រើប្រាស់អុសធ្យូង របស់ប្រជាកសិករនៅជនបទនៅតែបន្តកើតមាន ដែលទាមទារឱ្យមានការយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់ឡជីវឧស្ម័នកាន់តែទូលាយ។

## ១.៥. យុត្តិកម្មនៃការបង្កើតគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ន

ការបង្កើតគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥ គឺជាការចាំបាច់ និងមានសារៈសំខាន់បំផុតសម្រាប់បម្រើឱ្យគោលដៅ៤យ៉ាង÷

(ទី១) ជំរុញការសាងសង់ឡជីវឧស្ម័នក្នុងផលិតកម្មសត្វ សំដៅគ្រប់គ្រងលាមកសត្វ និងកាកសំណល់ពីសត្តឃាតដ្ឋានបានត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស ពង្រីកការផ្សព្វផ្សាយសម្រាប់ការបង្កើតនិងប្រើប្រាស់ឡជីវឧស្ម័ន និងប្រព័ន្ធកសិកម្មចម្រុះឱ្យកាន់តែទូលាយ និងបង្កើនសមត្ថភាពសហគមន៍ប្រើប្រាស់ឡជីវឧស្ម័ន ឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន និងកាត់បន្ថយចំណាយរបស់កសិករ។

(ទី២) លើកកម្ពស់គុណភាពឡជីវឧស្ម័ន និងប្រយោជន៍នៃការប្រើប្រាស់ឡជីវឧស្ម័ន ដោយត្រូវបង្កើន និងជំរុញការស្រាវជ្រាវនិងអភិវឌ្ឍន៍ផ្នែកឡជីវឧស្ម័ន ការពង្រឹងសមត្ថភាពបច្ចេកទេសក្នុងការសាងសង់ បង្កើតស្តង់ដារឡជីវឧស្ម័នឱ្យបានត្រឹមត្រូវ និងធានាបានការគ្រប់គ្រងគុណភាពឡជីវឧស្ម័នកាន់តែប្រសើរឡើង។

(ទី៣) បង្កើនការចូលរួមនិងលើកទឹកចិត្តពីរាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានាក្នុងការបង្កើនមូលនិធិសម្រាប់អនុវត្តកម្មវិធីឡជីវឧស្ម័នជាតិ ការផ្តល់បន្ថែមនូវការឧបត្ថម្ភធន ដើម្បីឱ្យការសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ននៅកម្ពុជា កាន់តែរីកសាយភាយទូទាំងប្រទេស។

(ទី៤) បង្កើនឥណទានកាបូនឱ្យកាន់តែច្រើនឡើង ដើម្បីជាប្រភពមូលនិធិអភិវឌ្ឍន៍ឡជីវឧស្ម័នមានលក្ខណៈនិរន្តរភាព ជួយដល់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងចីរភាពបរិស្ថាន។

ការបំភាយឧស្ម័នផ្ទះកញ្ចក់ទៅលើអាកាស បានរួមចំណែកធ្វើឱ្យផែនដីឡើងកម្តៅស្រទាប់អូហ្សូនកំពុងត្រូវបានថយចុះនៅលើពិភពលោក។ ការបង្កើនការសាងសង់ឡជីវឧស្ម័ននឹងជួយដល់ផ្នែកបរិស្ថានចូលរួមការកាត់បន្ថយការកើនឡើងកម្តៅផែនដីដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័នដែលនឹងត្រូវបានបង្កើតឡើងនេះ មានគោលបំណងផ្តល់ឱ្យអ្នកប្រើប្រាស់ឡទាំងនោះទទួលបាននូវអត្ថប្រយោជន៍ចំនួន៤យ៉ាងគឺ÷

១. <u>**អត្ថប្រយោជន៍សេដ្ឋកិច្ចដល់អ្នកប្រើប្រាស់**</u>÷ ការបង្កើនប្រាក់ចំណេញបន្ថែម ពីការសន្សំមិនទិញឧសឲ្យសម្រាប់ចម្អិនអាហារ កាត់បន្ថយការចំណាយលើការបំភ្លឺ និងមិនទិញជីគីមីប្រើលើដំណាំដោយការបង្កើនជីធម្មជាតិស្រស់ទឹកនិងគោកសម្រាប់ប្រើលើដំណាំកសិកម្ម ដែលជួយកែប្រែគុណភាពដីកសិកម្ម។

២. <u>**អត្ថប្រយោជន៍បរិស្ថាន**</u>÷ ជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីឧស្ម័នមេតាន និងកាត់បន្ថយឧស្ម័នកាបូនិកចំនួនប្រមាណ៤,៥ តោនក្នុងមួយឡក្នុងរយៈពេលមួយឆ្នាំ។

៣. <u>**អត្ថប្រយោជន៍ផ្នែកសុខភាព**</u>÷ ជួយកាត់បន្ថយក្លិនស្អុយពីការចិញ្ចឹមសត្វ ពិសេសសត្វជ្រូកលំនៅដ្ឋានមានអនាម័យល្អ គ្រប់គ្រងលាមកសត្វមិនរាយប៉ាយ និងធ្វើឱ្យផ្ទះអ្នកប្រើប្រាស់ឡជីវឧស្ម័នមានរបៀបរៀបរយ ដោយការតភ្ជាប់បង្គន់អនាម័យនឹងឡជីវឧស្ម័ន។

៤. <u>**អត្ថប្រយោជន៍ផ្នែកសង្គម**</u>÷ អ្នកប្រើប្រាស់ឡមានពេលវេលាចូលរួមក្នុងសង្គម មានពេលវេលាធ្វើការងារផ្សេងៗទៀត មានភ្លើងបំភ្លឺផ្ទះពេលយប់ ជួយដល់ការរៀនសូត្ររបស់កូនចៅ កាត់បន្ថយបន្ទុកការងារស្ត្រីនិងកុមារ ដោយមិនចាំបាច់ចូលព្រៃរកអុសច្រើន និងម៉្យាងទៀត បង្កើតបានការងារដល់អ្នកគ្មានការងារធ្វើក្នុងស្រុក តាមរយៈការបង្កើតឲ្យមានភ្នាក់ងារសាងសង់ឡជីវឧស្ម័ន ដែលកាត់បន្ថយចំណាកស្រុក។

បន្ថែមលើសពីនេះទៀត គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ន នឹងជាឧបករណ៍គោលនយោបាយសម្រាប់ជំរុញដល់ការអនុវត្តកម្មវិធីឡជីវឧស្ម័ន ដែលជាកម្មវិធីជាតិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ កម្មវិធីនេះមានគោលបំណងបង្កើតវិស័យឡជីវឧស្ម័ន តាមបែបពាណិជ្ជកម្មនិងទីផ្សារ ដើម្បីផ្សព្វផ្សាយពង្រីកការសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន ដែលជាប្រភពថាមពលកកើតឡើងវិញ និងមាននិរន្តរភាព។

## ២. ចក្ខុវិស័យ

"ប្រជាពលរដ្ឋនិងសហគមន៍ជនបទ ទទួលបានសុខភាពល្អ មានជីវភាពរស់នៅកាន់តែប្រសើរឡើង និងបរិស្ថានមាននិរន្តរភាព តាមរយៈការពង្រីកការចិញ្ចឹមសត្វ និងការប្រើប្រាស់ឡជីវឧស្ម័នប្រកបដោយប្រសិទ្ធភាព និងចីរភាពនៅកម្ពុជា"។

## ៣. គោលបំណងនិងគោលដៅ

### ៣.១ គោលបំណង

"លើកកម្ពស់ការអភិវឌ្ឍនិងប្រើប្រាស់ឡជីវឧស្ម័នប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព សំដៅផ្គត់ផ្គង់ថាមពលកកើតឡើងវិញនៅជនបទ និងធ្វើឱ្យប្រសើរឡើងផលិតកម្មកសិកម្ម ព្រមទាំងរួមចំណែកបង្កើនកម្រិតជីវភាពរស់នៅដល់ប្រជាកសិករ សហគមន៍ជនបទ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលនឹងចូលរួមអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាពក្នុងប្រទេសកម្ពុជា "។

### ៣.២ គោលដៅ

(ទី១) លើកកម្ពស់សមត្ថភាព និងបង្កើនការផ្សព្វផ្សាយបច្ចេកវិទ្យាឡជីវឧស្ម័ន ប្រកបដោយប្រសិទ្ធភាពដល់កសិករ សហគមន៍ប្រើប្រាស់ឡជីវឧស្ម័ន និងអ្នកពាក់ព័ន្ធ ដើម្បីបង្កើនការសាងសង់ឡជីវឧស្ម័នប្រកបដោយគុណភាពឲ្យបានទូលំទូលាយទូទាំងប្រទេស។

(ទី២) ពង្រីកការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាឡជីវឧស្ម័ន ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ សំដៅទាញយកអត្ថប្រយោជន៍ឡឲ្យបានអតិបរិមា។

(ទី៣) បង្កើនការគាំទ្រពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងជំរុញការវិនិយោគពីវិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត លើការអភិវឌ្ឍនិងបង្កើតឡជីវឧស្ម័ន ដើម្បីគ្រប់គ្រងកាកសំណល់សត្វប្រកបដោយប្រសិទ្ធភាពខ្ពស់។

(ទី៤) បង្កើនឥណទានកាបោន ដើម្បីគាំទ្រឲ្យមាននិរន្តរភាពនៃការអភិវឌ្ឍឡជីវឧស្ម័ន។

តារាងទី២÷ សូចនាករសមិទ្ធកម្មសំខាន់ៗត្រូវសម្រេចឱ្យបាននៅត្រឹមឆ្នាំ២០២៥

| សូចនាករ | ២០១៦[4] | ២០២០[5] | ២០២៥[6] |
|---|---|---|---|
| (១) ឧស្ម័នផ្ទះកញ្ចក់-ឧស្ម័នកាបូនិកត្រូវបានកាត់បន្ថយ (ពាន់តោន) | ៤៧០ | ៩៥១ | ១៦៨៩ |
| (២) បរិមាណអុសត្រូវបានកាត់បន្ថយ (ពាន់តោន) | ២៧៦ | ៤៨៩ | ៨១៨ |
| (៣) បរិមាណជីធម្មជាតិពីឡជីវឧស្ម័នត្រូវបានផលិត (ពាន់តោន) | ២០៧ | ៣៦៧ | ៦១៣ |

## ៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ឡជីវឧស្ម័ន

### ៤.១ ជំរុញការបង្កើតឡជីវឧស្ម័នក្នុងផលិតកម្មសត្វ

*(ទី១) បង្កើនការផ្សព្វផ្សាយបច្ចេកទេសសាងសង់និងប្រើប្រាស់ឡជីវឧស្ម័នដល់កសិករចិញ្ចឹមសត្វ*

ការចិញ្ចឹមសត្វភាគច្រើនគឺត្រូវបានអនុវត្តដោយគ្រួសារកសិករនៅជនបទ និងការប្រើប្រាស់អុសធ្យូងត្រូវបានសង្កេតឃើញថាមានការប្រើប្រាស់ច្រើន។ ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃឡជីវឧស្ម័នដល់កសិករចិញ្ចឹមសត្វនៅជនបទ គឺជាចំណុចគន្លឹះមួយដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់។ កសិករនឹងយល់ថាជីវឧស្ម័ន ដែលផលិតចេញពីឡជីវឧស្ម័ន ពិតជាអាចជួយដោះស្រាយបាននូវបញ្ហាកង្វះថាមពលសម្រាប់ចម្អិនអាហារជាប្រចាំថ្ងៃ និងជាពិសេសទៀតនោះ គឺអាចកាត់បន្ថយការពឹងផ្អែកលើការប្រើប្រាស់អុសធ្យូង ដែលប៉ះពាល់ដល់ចីរភាពនៃធនធានព្រៃឈើ។ លើសពីនេះទៀត កសិករនឹងអាចកាត់បន្ថយនូវចំណាយលើការប្រើប្រាស់ថាមពលប្រចាំថ្ងៃ។ យុទ្ធសាស្ត្របង្កើនការផ្សព្វផ្សាយបច្ចេកទេសសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័នដល់កសិករចិញ្ចឹមសត្វ គឺត្រូវបានជំរុញឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព។

[4] តួលេខសរុបគិតពីឆ្នាំ ២០០៦-២០១៦
[5] តួលេខសរុបគិតពីឆ្នាំ ២០១៦-២០២០
[6] តួលេខសរុបគិតពីឆ្នាំ ២០២០-២០២៥

ក្នុងគោលដៅបង្កើនបរិមាណឡជីវឧស្ម័ននៅជនបទឱ្យបានច្រើន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវផ្តោតការយកចិត្តទុកដាក់នូវចំណុចសំខាន់ៗមួយចំនួនគឺ÷ ១) បង្កើនការចិញ្ចឹមសត្វឱ្យមាននិរន្តរភាពដោយកសិករនៅជនបទ ដើម្បីជាមូលដ្ឋានផ្គត់ផ្គង់វត្ថុធាតុដើមសម្រាប់ផលិតថាមពល ២) បង្កើនការផ្សព្វផ្សាយឡជីវឧស្ម័ន ដើម្បីឱ្យកសិករចិញ្ចឹមសត្វយល់អំពីសារៈប្រយោជន៍នៃឡជីវឧស្ម័ន និងផ្តល់បច្ចេកទេសក្នុងការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន ៣) បង្កើនធនធាន ទាំងផ្នែកបច្ចេកទេស និងទាំងផ្នែកហិរញ្ញវត្ថុ សម្រាប់អនុវត្តការងារផ្សព្វផ្សាយឡជីវឧស្ម័នឱ្យមានប្រសិទ្ធភាពខ្ពស់។

### *(ទី២) ជំរុញនិងលើកទឹកចិត្តដល់អ្នកចិញ្ចឹមសត្វខ្នាតតូច មធ្យម និងធំ ក្នុងការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន និងអនុវត្តប្រព័ន្ធកសិកម្មចម្រុះ*

កសិដ្ឋានចិញ្ចឹមសត្វឯកជនខ្នាតតូច មធ្យម និងធំ មានការកើនឡើងក្នុងរយៈពេលចុងក្រោយនេះ។ ជាមួយគ្នានេះ ការបំភាយក្លិនកាកសំណល់ពីកសិដ្ឋានមួយចំនួន បានធ្វើឱ្យប៉ះពាល់ដល់អ្នករស់នៅជុំវិញ និងបំពុលបរិស្ថាន។ ក្នុងគោលដៅកាត់បន្ថយផលប៉ះពាល់ដែលបានកើតមាននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងលើកទឹកចិត្តឱ្យកសិដ្ឋានចិញ្ចឹមសត្វទាំងអស់ រៀបចំសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន។ វិធានការជាយុទ្ធសាស្ត្រចំនួន៤នឹងត្រូវបានដាក់ចេញគឺ÷ ១) បង្កើនការអប់រំផ្សព្វផ្សាយដល់គ្រប់ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វទាំងអស់ឱ្យយល់ដឹងកាន់តែទូលាយនូវសារៈសំខាន់ និងអត្ថប្រយោជន៍ផ្នែកសុខុមាលភាព សង្គម សេដ្ឋកិច្ច និងបរិស្ថាន នៃការប្រើប្រាស់ឡជីវឧស្ម័ន ២) ជំរុញឱ្យម្ចាស់កសិដ្ឋានចិញ្ចឹមសត្វរៀបចំសាងសង់ឡជីវឧស្ម័នស្របតាមស្តង់ដារកំណត់ ៣) លើកទឹកចិត្តដល់ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វ អនុវត្តនូវអភិក្រមអភិវឌ្ឍន៍ "ការផ្សារភ្ជាប់គ្នារវាងកសិដ្ឋានចិញ្ចឹមសត្វ ជាមួយការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ" សំដៅបង្កើនផលិតកម្មសត្វនិងផលិតផលកសិកម្មសរីរាង្គ ៤) បង្កើនការលើកទឹកចិត្តដល់ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វ តាមរយៈការផ្តល់វិញ្ញាបនបត្រសរសើរនិងលើកទឹកចិត្ត ក្រោយពីការត្រួតពិនិត្យស្តង់ដារបច្ចេកទេសឡជីវឧស្ម័ន។

### *(ទី៣) ជំរុញការសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន ដើម្បីគ្រប់គ្រងកាកសំណល់សត្តឃាតដ្ឋាន*

ជាការកត់សម្គាល់ កាកសំណល់ដែលចេញពីសត្តឃាតដ្ឋានភាគច្រើន នៅពុំទាន់បានគ្រប់គ្រងល្អប្រសើរនៅឡើយ ដែលនាំដល់ការបំពុលបរិស្ថានជុំវិញ។ ការគ្រប់គ្រងកាកសំណល់នេះ ទាមទារឱ្យមានការយកចិត្តខ្ពស់ពីម្ចាស់សត្តឃាតដ្ឋាន។ ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងដាក់ចេញ

នូវវិធានការគោលនយោបាយចំនួន៣ជាសំខាន់គឺ÷ ១) បង្កើនការផ្សព្វផ្សាយដល់ម្ចាស់សត្តឃាតដ្ឋាននៅទូទាំងប្រទេស ឱ្យយល់ដឹងពីផលប្រយោជន៍នៃការប្រើប្រាស់ឡជីវឧស្ម័ន ២) ជំរុញការសាងសង់ឡជីវឧស្ម័ននៅតាមសត្តឃាតដ្ឋាន ស្របតាមស្តង់ដារកំណត់ ៣) បង្កើនការគាំទ្រនិងលើកទឹកចិត្តដល់ម្ចាស់សត្តឃាតដ្ឋាន តាមរយៈការផ្តល់វិញ្ញាបនបត្រសរសើរនិងលើកទឹកចិត្ត ក្រោយពីការត្រួតពិនិត្យស្តង់ដារបច្ចេកទេសឡជីវឧស្ម័ន។

### *(ទី៤) បង្កើតនិងជំរុញសហគមន៍ប្រើប្រាស់ឡជីវឧស្ម័ន*

ការប្រមូលចងក្រងជាក្រុមឬសហគមន៍ប្រើប្រាស់ឡជីវឧស្ម័ន គឺជាមូលដ្ឋាន គ្រឹះសម្រាប់ការទទួលបាននូវព័ត៌មាន ចំណេះដឹងបច្ចេកទេស បទពិសោធន៍នានា ទាក់ទងនឹងការអភិវឌ្ឍឡជីវឧស្ម័ន ដែលនឹងត្រូវបានផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកពាក់ព័ន្ធផ្នែកឡជីវឧស្ម័នទាំងអស់។ វិធានការជាយុទ្ធសាស្ត្រចំនួន៤នឹងត្រូវបានដាក់ចេញ ដើម្បីជំរុញការបង្កើតនិងលើកកម្ពស់សមត្ថភាពសហគមន៍ប្រើប្រាស់ឡជីវឧស្ម័ន រួមមាន÷ ១) បង្កើនការផ្សព្វផ្សាយដល់កសិករចិញ្ចឹមសត្វ បានយល់ដឹងពីផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍ប្រើប្រាស់ឡជីវឧស្ម័ន ២) បង្កើនការគាំទ្រទាំងផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុ ក្នុងការរៀបចំបង្កើតសហគមន៍ប្រើប្រាស់ឡជីវឧស្ម័ន ៣) ធានានិរន្តរភាពនៃសហគមន៍ប្រើប្រាស់ឡជីវឧស្ម័ន តាមរយៈការជួយឧបត្ថម្ភគាំទ្រដើម្បីបង្កើនជំនាញបច្ចេកទេសប្រើប្រាស់ឡជីវឧស្ម័ន ៤) ជំរុញឱ្យសហគមន៍អនុវត្តនូវប្រព័ន្ធកសិកម្មចម្រុះ សំដៅបង្កើនផលិតកម្មសត្វផង និងផលិតផលកសិកម្មសរីរាង្គផង ព្រមទាំងបង្កើតបណ្តាញទីផ្សារផលិតផលកសិកម្មសរីរាង្គ។

តារាងទី៣÷ សូចនាករលទ្ធផលសំខាន់ៗត្រូវសម្រេចឱ្យបាននៅត្រឹមឆ្នាំ២០២៥

| សូចនាករ | ២០១៦[7] | ២០២០[8] | ២០២៥[9] |
|---|---|---|---|
| (១) ចំនួនឡជីវឧស្ម័នលក្ខណៈគ្រួសារត្រូវបានសាងសង់ (ពាន់ឡ) | ២៥ | ៣៣ | ៤៣ |
| (២) ចំនួនឡជីវឧស្ម័នខ្នាតមធ្យមត្រូវបានសាងសង់ (ឡ) (លាមកសត្វចំនួន១៥០០-១២០០០គីឡូក្រាម) | ១០០ | ២០០ | ៥០០ |
| (៣) ចំនួនឡជីវឧស្ម័នខ្នាតធំត្រូវបានសាងសង់ (ឡ) | ១ | ៣ | ៥ |

| | | | |
|---|---|---|---|
| (លាមកសត្វចំនួន១២០០០គីឡូក្រាមឡើងទៅ) | | | |
| (៤) ចំនួនសត្តឃាតដ្ឋានមានឡជីវឧស្ម័ន (ឡ) | ០៥ | ២៥ | ៥០ |
| (៥) ចំនួនសហគមន៍ប្រើប្រាស់ឡជីវឧស្ម័នត្រូវបង្កើត (សហគមន៍) | ០១ | ៥ | ១០ |

## ៤.២ លើកកម្ពស់គុណភាពឡជីវឧស្ម័ន និងប្រយោជន៍ឡជីវឧស្ម័ន

### *(ទី១) ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍន៍ការសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន*

ប្រសិទ្ធភាពនិងគុណភាពនៃឡជីវឧស្ម័ននឹងត្រូវតែបានបង្កើនឡើង សំដៅដល់ការកាត់បន្ថយនូវការចំណាយក្នុងការសាងសង់ និងអាចប្រើប្រាស់បានយូរ។ ក្នុងន័យនេះ ការស្រាវជ្រាវនិងអភិវឌ្ឍន៍ការសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន គឺជាគន្លឹះសំខាន់មួយដែលត្រូវតែទទួលបាននូវការគាំទ្រខ្ពស់ ទាំងផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់គុណភាពឡជីវឧស្ម័ន និងប្រយោជន៍ឡជីវឧស្ម័ន។ ក្នុងទិសដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវផ្តោតជាសំខាន់នូវការអនុវត្តវិធានការជាយុទ្ធសាស្ត្រចំនួន៤គឺ៖ ១) លើកម្ពស់សមត្ថភាពបច្ចេកទេសដល់មន្ត្រីជំនាញផ្នែកអភិវឌ្ឍន៍ឡជីវឧស្ម័ន ដោយត្រូវបង្កើនការផ្តល់ចំណេះដឹងបច្ចេកទេស ការចែករំលែកបទពិសោធន៍ ២) បង្កើនការស្រាវជ្រាវនិងអភិវឌ្ឍន៍ឡជីវឧស្ម័ន ក៏ដូចជាការសិក្សាពិសោធន៍សម្រាប់បង្កើតបាននូវនវានុវត្តន៍ និងរបកគំហើញថ្មីៗ ៣) បង្កើនការផ្សព្វផ្សាយនូវបច្ចេកវិទ្យាទំនើប ដែលបានស្រាវជ្រាវរកឃើញ ដល់មន្ត្រីជំនាញឡជីវឧស្ម័ន ដើម្បីធ្វើការផ្សព្វផ្សាយបន្តដល់អ្នកសាងសង់ឡជីវឧស្ម័ន ៤) ពិនិត្យនិងកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធស្ថាប័ន ក្នុងគោលដៅបង្កើតនូវអង្គភាពឬវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ឡជីវឧស្ម័ន។

### *(ទី២) បង្កើនការពង្រឹងសមត្ថភាពបច្ចេកទេសសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន*

សមត្ថភាពបច្ចេកទេសសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន គឺជាចំណុចជាយុទ្ធសាស្ត្រសំខាន់មួយបន្ថែមទៀត សម្រាប់ការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា។ ក្នុងទិសដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវផ្តោតជាសំខាន់នូវការអនុវត្តវិធានការជាយុទ្ធសាស្ត្រចំនួន៥គឺ៖ ១) បង្កើនការយកចិត្តទុកដាក់លើការសិក្សានិងវាយតម្លៃច្បាស់លាស់ នូវតម្រូវការពង្រឹងសមត្ថភាពដល់មន្ត្រីបច្ចេកទេសជំនាញកសិករចិញ្ចឹមសត្វ អ្នកសាងសង់ឡជីវឧស្ម័ន និងអ្នកពាក់ព័ន្ធផ្សេងទៀត ២) បង្កើនធនធានថវិកាសម្រាប់កម្មវិធីបណ្តុះបណ្តាលពាក់ព័ន្ធនឹងការអភិវឌ្ឍឡជីវឧស្ម័ន ៣) បង្កើតប្រព័ន្ធព័ត៌មានវិទ្យាស្តីពីបច្ចេកទេសសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន និងផ្សព្វផ្សាយឱ្យបានទូលាយដល់អ្នកពាក់ព័ន្ធទាំងអស់នៅទូទាំង

ប្រទេស ៤)ពង្រីកចំណេះដឹងនិងជំនាញបច្ចេកទេសឡជីវឧស្ម័នដល់យុវវ័យ តាមរយៈកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំកសិកម្មនានា ៥) លើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីអនុវត្តនូវកម្មវិធីបណ្តុះបណ្តាលអំពីការអភិវឌ្ឍ និងការប្រើប្រាស់ឡជីវឧស្ម័ន។

*(ទី៣) លើកកម្ពស់ការគ្រប់គ្រងគុណភាពឡជីវឧស្ម័នស្របតាមនិយាមបច្ចេកទេស*

ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យគុណភាពឡជីវឧស្ម័ន ស្តង់ដារឡជីវឧស្ម័នគឺជាឧបករណ៍មួយសម្រាប់ប្រើប្រាស់និងអនុវត្ត។ ក្នុងទិសដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវផ្តោតជាសំខាន់នូវការអនុវត្តវិធានការជាយុទ្ធសាស្ត្រចំនួន៣គឺ÷ ១) បង្កើតនិងអនុវត្តនូវស្តង់ដារឡជីវឧស្ម័ន ២) ពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងគុណភាពឡជីវឧស្ម័នស្របតាមស្តង់ដារឡជីវឧស្ម័ន ៣) បង្កើនការត្រួតពិនិត្យគុណភាពឡជីវឧស្ម័ន។

## ៤.៣ លើកកម្ពស់ការលើកទឹកចិត្ត និងការឧបត្ថម្ភធន

ក្នុងគោលដៅជំរុញការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជាឱ្យមានការរីកចម្រើន ការចូលរួមគាំទ្រទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន គឺជាកិច្ចការគន្លឹះដែលត្រូវយកចិត្តទុកដាក់ខ្ពស់។ ប្រជាកសិករចិញ្ចឹមសត្វត្រូវការនូវការគាំទ្រនេះ ពិសេសការទទួលបានឧបត្ថម្ភធនសម្រាប់ការសាងសង់ឡជីវឧស្ម័នរបស់ពួកគាត់។ ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងខិតខំប្រឹងប្រែង ដើម្បីកៀរគរធនធានហិរញ្ញប្បទានទាំងអស់ សម្រាប់ការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា។

ជាមួយគ្នានេះ បណ្តាដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដែលធ្វើការងារពាក់ព័ន្ធនឹងការអភិវឌ្ឍឡជីវឧស្ម័ន នឹងត្រូវបានទទួលការលើកទឹកចិត្តពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការជួយសម្របសម្រួលគ្រប់បែបយ៉ាងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ដើម្បីសម្រេចនូវទិសដៅនេះ វិធានការគោលនយោបាយចំនួន៥នឹងត្រូវដាក់ចេញគឺ÷

(ទី១) បង្កើនធនធានហិរញ្ញវត្ថុ និងវិភាជថវិកាជាតិឱ្យកើនពីក្នុងរង្វង់៤% នៅឆ្នាំ២០១៦ ដល់ ១០% យ៉ាងតិច នៅឆ្នាំ២០២៥ នៃថវិកាជាតិហិរញ្ញប្បទានទ្រទ្រង់កម្មវិធីជំរុញផលិតកម្មសត្វនិងសុខភាពសត្វ សម្រាប់ចូលរួមចំណែកអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា។

(ទី២) ធានាការចូលរួមឧបត្ថម្ភធនដល់កសិករចិញ្ចឹមសត្វ ដែលអនុវត្តការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន ដោយត្រូវផ្តល់ធនធានថវិកាទាបបំផុតប្រមាណ ៣០% នៃតម្លៃសាងសង់ក្នុងមួយឡជីវឧស្ម័ន ដើម្បីលើកទឹកចិត្តក្នុងចូលរួមពីកសិករ។

(ទី៣) លើកទឹកចិត្តដល់បណ្តាដៃគូអភិវឌ្ឍន៍ ចូលរួមឱ្យបានសស្រាក់សស្រាំ ក្នុងការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា ដោយត្រូវវិភាជធនធានហិរញ្ញវត្ថុក្នុងកម្រិត១០% យ៉ាងតិច នៃគម្រោងអភិវឌ្ឍន៍ក្នុងកម្មវិធីជំរុញផលិតកម្មសត្វនិងសុខភាពសត្វ សម្រាប់ចូលរួមអភិវឌ្ឍន៍ឡជីវឧស្ម័ននេះ។

(ទី៤) លើកទឹកចិត្តនិងជំរុញឱ្យវិស័យឯកជន ពិសេសកសិដ្ឋានចិញ្ចឹមសត្វ និងសត្តឃាតដ្ឋានទាំងអស់ ចូលរួមសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន និងផ្តល់នូវបទពិសោធន៍ដល់កសិករចិញ្ចឹមសត្វខ្នាតតូចនិងមធ្យម បានយល់ដឹងពីការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន។ លើសពីនេះទៀត ការលើកលែងពន្ធនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ឡជីវឧស្ម័ននឹងត្រូវបានស្នើសុំអនុគ្រោះ ដើម្បីលើកទឹកចិត្តដល់វិស័យឯកជន។

(ទី៥) បង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារក្នុងការផ្តល់ប្រាក់កម្ចីដល់កសិករ ដើម្បីគាំទ្រសកម្មភាពអភិវឌ្ឍន៍ឡជីវឧស្ម័នពិសេសការជំរុញឱ្យមានការបញ្ចុះការប្រាក់ក្នុងកម្រិតមួយសមស្រប។

## ៤.៤ បង្កើនទីផ្សារឥណទានកាបោន ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់

ការបង្កើនទីផ្សារឥណទានកាបោន គឺជាវិធានការជាយុទ្ធសាស្ត្រមួយដ៏សំខាន់ ក្នុងការកៀរគរធនធានថវិកាសម្រាប់ការអភិវឌ្ឍឡជីវឧស្ម័ន។ នៅពេលដែលឡជីវឧស្ម័នត្រូវបានបង្កើតឡើងកាន់តែច្រើន ការបំភាយឧស្ម័នផ្ទះកញ្ចក់ក៏ត្រូវបានកាត់បន្ថយច្រើនផងដែរ។ លើសពីនេះទៀតនោះ ឡជីវឧស្ម័នដែលជាសក្តានុពលទាំងនេះ នឹងអាចទាក់ទាញបណ្តាប្រទេសជាដៃគូអភិវឌ្ឍន៍ ចូលរួមផ្តល់ហិរញ្ញប្បទានសម្រាប់និរន្តរភាពនៃការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា។ ដើម្បីសម្រេចនូវទិសដៅនេះ វិធានការគោលនយោបាយចំនួន២នឹងត្រូវដាក់ចេញគឺ÷ ១) បង្កើនការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់បណ្តាប្រទេសអភិវឌ្ឍន៍អំពីការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា និងកៀរគរធនធានឱ្យច្រើន សម្រាប់ចូលរួមចំណែកសាងសង់ឡជីវឧស្ម័នបន្ថែមទៀតឱ្យបានកាន់តែច្រើនឡើង ២)រៀបចំនិងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ នូវស្តង់ដារឡជីវ

ឧស្ម័នកម្ពុជា ដោយបង្ហាញច្បាស់លាស់អំពីលក្ខណៈបច្ចេកទេសនៃឡជីវឧស្ម័ន លក្ខខណ្ឌសាងសង់ ការគ្រប់គ្រងគុណភាព ការធានា និងការបណ្ដុះបណ្ដាលដល់អ្នកប្រើប្រាស់។

# ៥. វិធានការគោលនយោបាយនិងផែនការសកម្មភាព

## ៥.១. ការរៀបចំស្ថាប័ននិងសម្របសម្រួល

### ក) គណៈកម្មាធិការប្រឹក្សាយោបល់ថ្នាក់ជាតិ

គណៈកម្មាធិការប្រឹក្សាយោបល់ថ្នាក់ជាតិ គឺជាយន្តការសម្របសម្រួលមួយដ៏មានប្រសិទ្ធភាព សម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥។ គណៈកម្មាធិការនេះ នឹងត្រូវបានបង្កើតឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមាន សមាសភាពដូចខាងក្រោម÷

| | |
|---|---|
| – រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| – អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| – អគ្គលេខាធិការ/អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធានអចិន្ត្រៃយ៍ |
| – ប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| – ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកអចិន្ត្រៃយ៍ |
| – តំណាងដៃគូអភិវឌ្ឍន៍ | សមាជិក |
| – តំណាងផ្នែកឯកជន | សមាជិក |

គណៈកម្មាធិការប្រឹក្សាយោបល់ថ្នាក់ជាតិ នឹងត្រូវអនុវត្តភារកិច្ចសំខាន់ៗជាអាទិភាពមួយចំនួន ដូចខាងក្រោម÷

- សម្របសម្រួល និងតម្រង់ទិសក្នុងការអនុវត្ត គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅ កម្ពុជាឆ្នាំ២០១៦-២០២៥ ឱ្យសម្រេចជោគជ័យ តាមគោលបំណងនិងគោលដៅ ដូចមាន ចែងក្នុងគោលនយោបាយនេះ

- ពិនិត្យនិងអនុម័តលើផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ផែនការរយៈពេល៣ឆ្នាំ និង ៥ឆ្នាំ ដែលស្នើឡើងដោយក្រុមការងារបច្ចេកទេសថ្នាក់ជាតិនិងថ្នាក់ខេត្ត សំដៅធានាថា សកម្មភាពទាំងឡាយដែលបានស្នើឡើង ឆ្លើយតបទៅនឹងគោលនយោបាយនេះ
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ក្រោមយន្តការក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក (Technical Working Group on Agriculture and Water) និងយន្តការផ្សេងទៀត ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ និងជំរុញការអភិវឌ្ឍឡូជីវឧស្ម័ននៅកម្ពុជា ឱ្យមានប្រសិទ្ធភាពនិងចីរភាព
- ពិនិត្យតាមដានលើការអនុវត្តផែនការសកម្មភាព សំដៅធានាថាការអនុវត្តរបស់អង្គភាពជំនាញពាក់ព័ន្ធមានប្រសិទ្ធភាពខ្ពស់។

### ២) ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ

ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ គឺជាយន្តការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡូជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥។ ក្រុមការងារបច្ចេកទេសនេះ នឹងត្រូវបានបង្កើតឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| - អគ្គលេខាធិការរង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| - ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| - ប្រធានការិយាល័យពាក់ព័ន្ធនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល | សមាជិក |
| - អ្នកសម្របសម្រួលកម្មវិធីឡូជីវឧស្ម័នជាតិ | សមាជិក |
| - ប្រធានការិយាល័យគ្រប់គ្រងកាកសំណល់សត្វ | សមាជិកអចិន្ត្រៃយ៍ |
| - ក្រុមទីប្រឹក្សានៃកម្មវិធីឡូជីវឧស្ម័នជាតិ អមនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល | អ្នកសង្កេតការណ៍ |

ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ត្រូវអនុវត្តភារកិច្ចសំខាន់ៗមួយចំនួនដូចខាងក្រោម÷

- រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ៣ឆ្នាំ និង៥ឆ្នាំ ដើម្បីអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥ សម្រាប់អនុវត្តឱ្យសម្រេចជោគជ័យ
- អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវផែនការសកម្មភាពដែលបានអនុម័ត គ្រប់គ្រងនិងប្រើប្រាស់មូលនិធិឡជីវឧស្ម័នជាតិឱ្យមានតម្លាភាព ដោយបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត សំដៅធ្វើឱ្យសាយភាយនូវការប្រើប្រាស់ឡជីវឧស្ម័នក្នុងប្រទេសកម្ពុជា
- សម្របសម្រួលក្នុងការអនុវត្តកម្មវិធីឡជីវឧស្ម័នជាតិ ឱ្យមានលក្ខណៈល្អប្រសើរ មានតម្លាភាព និងប្រសិទ្ធភាពខ្ពស់
- ពិនិត្យតាមដានលើការអនុវត្តផែនការសកម្មភាព ដែលអនុវត្តដោយក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត សំដៅធានាថាការអនុវត្តរបស់អង្គភាពជំនាញពាក់ព័ន្ធថ្នាក់ខេត្ត ស្រុក មានប្រសិទ្ធភាពខ្ពស់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើតការិយាល័យគ្រប់គ្រងកាកសំណល់សត្វ និងឡជីវឧស្ម័ន នៅក្នុងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល សម្រាប់ជាសេនាធិការផ្ទាល់ឱ្យក្រុមការងារបច្ចេកទេសថ្នាក់ជាតិ។

### គ) ក្រុមការងារបច្ចេកទេសថ្នាក់រាជធានី ខេត្ត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើតក្រុមការងារបច្ចេកទេសថ្នាក់រាជធានីខេត្ត ដើម្បីជួយសម្របសម្រួល និងអនុវត្តផែនការសកម្មភាពនៅថ្នាក់មូលដ្ឋាន សម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥។ ប្រធានមន្ទីរកសិកម្មខេត្តជាប្រធានក្រុមការងារ ប្រធានការិយាល័យផលិតនិងបសុព្យាបាលជាអនុប្រធាន និងមានការចូលរួមពីមន្ត្រីគ្រប់ការិយាល័យជំនាញពាក់ព័ន្ធ រួមទាំងមន្ត្រីជំនាញរបស់ការិយាល័យកសិកម្មស្រុកផងដែរ។

ក្រុមការងារបច្ចេកទេសថ្នាក់រាជធានីខេត្ត នឹងត្រូវចូលរួមអនុវត្តនូវបណ្តាសកម្មភាពការងារជាអាទិភាពដូចខាងក្រោម÷

- រៀបចំផែនការសកម្មភាពនិងថវិការបស់ខេត្តជាប្រចាំឆ្នាំ ស្របតាមការណែនាំរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ដើម្បីចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥
- អនុវត្តផែនការសកម្មភាពដែលបានអនុម័ត ដោយសហការយ៉ាងជិតស្និតជាមួយកម្មវិធីឡជីវឧស្ម័នជាតិ និងសម្របសម្រួលអនុវត្តបច្ចេកទេស ពីក្រុមទីប្រឹក្សាបច្ចេកទេសនៃកម្មវិធីឡជីវឧស្ម័នជាតិ
- ពិនិត្យតាមដានលើការអនុវត្តសកម្មភាពការងារបង្កើត និងប្រើប្រាស់ឡជីវឧស្ម័ននៅថ្នាក់ស្រុក
- សហការជាមួយក្រុមប្រឹក្សាឃុំសង្កាត់ ដើម្បីដាក់បញ្ចូលថវិកាកសាងឡជីវឧស្ម័នទៅក្នុងផែនការវិនិយោគឃុំសង្កាត់ និងត្រូវផ្តល់បច្ចេកទេសសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ននៅថ្នាក់មូលដ្ឋានឃុំសង្កាត់។

### ឃ) យន្តការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍

ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក (Technical Working Group on Agriculture and Water) គឺជាយន្តការសម្របសម្រួលរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹកនិងឧតុនិយម ជាមួយដៃគូអភិវឌ្ឍន៍ដែលធ្វើការងារពាក់ព័ន្ធនឹងវិស័យកសិកម្មនិងទឹក។ ក្រុមការងារនេះដឹកនាំការសម្របសម្រួល (ជាសហប្រធាន) ដោយរដ្ឋលេខាធិការនៃក្រសួងទាំងពីរ និងសហអ្នកសម្របសម្រួលពីរូបពីតំណាងដៃគូអភិវឌ្ឍន៍។ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក បានរៀបចំឱ្យមានកិច្ចប្រជុំពិគ្រោះយោបល់ពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍កសិកម្មនិងធនធានទឹក និងបានរួមគ្នាដោះស្រាយប្រកបដោយប្រសិទ្ធភាព នូវកិច្ចការអភិវឌ្ឍន៍ក្នុងវិស័យទាំងពីរនេះ។

ក្រោមក្របខ័ណ្ឌអនុវត្តយន្តការនៃក្រុមការងារបច្ចេកទេសកសិកម្មនិងទឹកនេះ អនុក្រុមការងារបច្ចេកទេសផ្នែកផលិតកម្មសត្វ (Sub-Group on Livestock in TWG-AW) ត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលដោយឡែក ពាក់ព័ន្ធនឹងការជំរុញផលិតកម្មសត្វនិងសុខភាពសត្វ។

ក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥ កិច្ចការគាំទ្រផ្នែកបច្ចេកទេស និងក្របខ័ណ្ឌឯកសារគតិយុត្តមួយចំនួន នឹងត្រូវមានការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍

បន្ថែមក្រោមយន្តការនៃក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក និងការឧបត្ថម្ភគាំទ្រធនធាន ទាំងផ្នែកបច្ចេកទេសនិងធនធានថវិកានឹងត្រូវបានបង្កើនឡើង ដើម្បីអនុវត្តគោលនយោបាយនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

## ៥.២ ក្របខ័ណ្ឌគតិយុត្ត

ក្នុងទិសដៅជំរុញការអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវរៀបចំកសាងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់សម្របសម្រួលក្នុងការងារគ្រប់គ្រង និងអនុវត្ត ដែលមានដូចខាងក្រោម÷

- រៀបចំប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីការបង្កើតគណៈកម្មាធិការប្រឹក្សាយោបល់ថ្នាក់ជាតិ ដើម្បីសម្របសម្រួលអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥
- រៀបចំប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីការបង្កើតក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ដើម្បីអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥
- រៀបចំសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីការបង្កើតក្រុមការងារបច្ចេកទេសថ្នាក់រាជធានីខេត្ត ដើម្បីជួយសម្របសម្រួល និងអនុវត្តផែនការសកម្មភាពនៅថ្នាក់មូលដ្ឋាន សំដៅចូលរួមដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥
- រៀបចំប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតមូលនិធិទ្រទ្រង់កម្មវិធីឡជីវឧស្ម័នជាតិ

## ៥.៣ ការគាំទ្រហិរញ្ញវត្ថុ

មូលនិធិទ្រទ្រង់កម្មវិធីឡជីវឧស្ម័នជាតិនឹងត្រូវបានបង្កើតឡើង សម្រាប់ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ក្នុងក្របខ័ណ្ឌកម្មវិធីឡជីវឧស្ម័នជាតិ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត នឹងខិតខំសហការបង្កើត និងដំណើរការអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងការប្រើប្រាស់មូលនិធិនេះ។

ថវិកាជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា នឹងជាប្រភពចម្បងក្នុងការផ្តល់ហិរញ្ញប្បទានដល់ការអនុវត្តសកម្មភាពជាក់ស្តែងនានា ដូចមានចែងលម្អិតក្នុងផែនការសកម្មភាពនិងថវិកា តាមយន្តការថវិកាកម្មវិធីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មូលនិធិពីដៃគូអភិវឌ្ឍន៍ សម្រាប់ចូលរួមបន្ថែមក្នុងមូលនិធិទ្រទ្រង់កម្មវិធីឡជីវឧស្ម័នជាតិ ក៏ជាប្រភពដ៏សំខាន់មួយទៀត ដើម្បីអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធកិច្ចការនេះ ចូលរួមផ្តល់មូលនិធិសម្រាប់គាំទ្រមូលនិធិទ្រទ្រង់កម្មវិធីឡជីវឧស្ម័នជាតិ និងចូលរួមអនុវត្តឱ្យបានសស្រាក់សស្រាំ និងមានប្រសិទ្ធភាពខ្ពស់។ អង្គការមិនមែនរដ្ឋាភិបាល គឺជាដៃគូយ៉ាងជិតស្និតជាមួយរាជរដ្ឋាភិបាល ពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការចូលរួមអនុវត្តគោលនយោបាយនេះ។ រាល់គម្រោងអភិវឌ្ឍន៍កសិកម្ម និងជនបទ ដែលអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន និងគាំទ្រហិរញ្ញប្បទានពីបណ្តាដៃគូអភិវឌ្ឍន៍ ក៏ត្រូវបានលើកទឹកចិត្តផងដែរ ក្នុងការបញ្ចូលសកម្មភាពសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន។

វិស័យឯកជន ពិសេសកសិដ្ឋានចិញ្ចឹមសត្វ សត្តឃាតដ្ឋានដែលមានកាកសំណល់សត្វច្រើន តម្រូវឱ្យមានការបង្កើតឡជីវឧស្ម័ន ដើម្បីគ្រប់គ្រងកាកសំណល់សត្វបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងប្រើប្រាស់ធនធានថវិការបស់ខ្លួនផ្ទាល់។ អង្គភាពជំនាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងជួយសម្របសម្រួលផ្តល់បច្ចេកទេសតាមការចាំបាច់ និងត្រូវចុះណែនាំឱ្យមានការបង្កើតឡជីវឧស្ម័ននៅតាមកសិដ្ឋានចិញ្ចឹមសត្វនិងសត្តឃាតដ្ឋាន។ ប្រភពធនធានថវិកាពីធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ គឺជាប្រភពមួយមិនចេះរីងស្ងួត សម្រាប់កសិករចិញ្ចឹមសត្វបង្កើនផលិតកម្មសត្វ ក៏ដូចជាការសាងសង់ឡជីវឧស្ម័ននៅជនបទ។

ក្នុងទិសដៅជំរុញការបង្កើតឡជីវឧស្ម័ននៅកម្ពុជា ឱ្យមានការរីកសាយទូលាយទូទាំងប្រទេស យន្តការដ៏សំខាន់មួយទៀត គឺការបង្កើនធនធានថវិកាឃុំ ក្រោមក្របខ័ណ្ឌផែនការវិនិយោគឃុំ ត្រូវបានជំរុញឱ្យមានការបង្កើនឡើង សម្រាប់ចូលរួមអនុវត្តគោលនយោបាយនេះ។ មន្ទីរកសិកម្មខេត្ត ត្រូវបង្កើនការផ្សព្វផ្សាយដល់ក្រុមប្រឹក្សាឃុំ អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ឡជីវឧស្ម័ន និងជំរុញឱ្យដាក់បញ្ចូលថវិកាមួយចំនួន សម្រាប់អនុវត្តការងារនេះ ក្នុងថវិកាវិនិយោគឃុំជាប្រចាំឆ្នាំ ដោយកំណត់យកចំណុចដៅត្រូវសាងសង់យ៉ាងតិចមួយ (០១) ឡក្នុងមួយឆ្នាំក្នុងមួយឃុំ។

ក្នុងគោលដៅនិរន្តរភាពយូរអង្វែងក្នុងការអភិវឌ្ឍន៍ឡជីវឧស្ម័ន ឥណទានកាបោនគឺជាប្រភពសំខាន់ដែលត្រូវយកចិត្តទុកដាក់ខ្ពស់ ក្នុងបរិបទនៃការអភិវឌ្ឍប្រកបដោយចីរភាព។ មូលនិធិទ្រទ្រង់កម្មវិធីឡជីវឧស្ម័នជាតិ ពឹងផ្អែកយ៉ាងខ្លាំងលើឥណទានកាបោន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបណ្តាដៃគូអភិវឌ្ឍន៍ ក៏ដូចជាអ្នកពាក់ព័ន្ធនានា ត្រូវខិតខំស្វះស្វែងរកទីផ្សារលក់កាបោន ដែលបានមកពីអត្ថប្រយោជន៍នៃការសាងសង់និងប្រើប្រាស់ឡជីវឧស្ម័ន សម្រាប់បង្កើនទុនមូលនិធិនេះ។

## ៥.៤ ការពង្រឹងសមត្ថភាពធនធានមនុស្ស

សមត្ថភាពធនធានមនុស្សក្នុងកិច្ចការអភិវឌ្ឍន៍ឡជីវឧស្ម័ន គឺជាកត្តាគន្លឹះនិងចាំបាច់បំផុត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវជំរុញឱ្យអនុវត្តនូវការងារជាអាទិភាពមួយចំនួនដូចខាងក្រោម÷

- រៀបចំនិងអនុវត្តផែនការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពបច្ចេកទេសអភិវឌ្ឍន៍ឡជីវឧស្ម័នដល់មន្ត្រីបច្ចេកទេស និងអ្នកពាក់ព័ន្ធទាំងអស់ ពិសេសកម្មវិធីបណ្តុះបណ្តាលមានចែងក្នុងកម្មវិធីឡជីវឧស្ម័នជាតិ
- បញ្ចូលកម្មវិធីសិក្សានិងប្រធានបទស្តីពីការអភិវឌ្ឍឡជីវឧស្ម័នក្នុងកម្មវិធីបណ្តុះបណ្តាល នៅតាមគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលកសិកម្ម (សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និងសាលាជាតិកសិកម្មកំពង់ចាម)
- បង្កើនការវិនិយោគលើគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលកសិកម្ម ដើម្បីធានាឱ្យមានធនធានមនុស្សគ្រប់គ្រាន់ក្នុងការអភិវឌ្ឍបច្ចេកវិទ្យាសាងសង់ និងគ្រប់គ្រងឡជីវឧស្ម័ននៅកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់
- បង្កើតកម្មវិធីផ្សព្វផ្សាយពង្រឹងសមត្ថភាពដល់ក្រុមជាងសាងសង់ឡជីវឧស្ម័ន និងត្រូវរៀបចំឱ្យមានទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ រវាងក្រុមជាងសាងសង់ឡជីវឧស្ម័ន ដើម្បីធានានូវភាពស័ក្តិសិទ្ធ ប្រសិទ្ធភាព និងកាត់បន្ថយចំណាយថ្លៃដើមក្នុងការកសាងឡជីវឧស្ម័ន
- សម្របសម្រួលនិងទំនាក់ទំនង ដើម្បីទទួលបានអាហារូបករណ៍សម្រាប់ការសិក្សា ដកស្រង់បទពិសោធន៍ ទាក់ទងនឹងការពង្រឹងសមត្ថភាពបច្ចេកទេសអភិវឌ្ឍន៍ឡជីវឧស្ម័ន ដល់មន្ត្រីបច្ចេកទេស និងអ្នកពាក់ព័ន្ធគ្រប់កម្រិត។

### ៥.៥ ដំណើរការអនុវត្តគោលនយោបាយ

ក្នុងក្របខ័ណ្ឌនៃការអនុវត្តគោលនយោបាយនេះ "កម្មវិធីឡជីវឧស្ម័នជាតិ" គឺជាយន្តការដ៏មានប្រសិទ្ធភាព ដើម្បីសម្រេចបាននូវគោលបំណងនិងគោលដៅ ដែលបានកំណត់និងដាក់ចេញឱ្យអនុវត្ត។ ផែនការសកម្មភាពនិងថវិកា រយៈពេល៥ឆ្នាំ ៣ឆ្នាំ និងប្រចាំឆ្នាំ នឹងត្រូវបានរៀបចំឡើង ដើម្បីកំណត់ច្បាស់លាស់នូវសកម្មភាពជាអាទិភាព អ្នកចូលរួមអនុវត្ត និងអ្នកទទួលខុសត្រូវជាក់លាក់។ កម្មវិធីឡជីវឧស្ម័នជាតិ នឹងត្រូវបានរៀបចំដោយក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត ក្រោមជំនួយបច្ចេកទេសនិងថវិកាពីអង្គភាពសម្របសម្រួល នៃកម្មវិធីឡជីវឧស្ម័នជាតិ។

ការអនុវត្តគោលនយោបាយនេះ នឹងត្រូវសម្របសម្រួលដោយ គណៈកម្មាធិការប្រឹក្សាយោបល់ថ្នាក់ជាតិ ។ គណៈកម្មាធិការនេះ នឹងពិនិត្យអនុម័ត លើផែនការសកម្មភាព និងថវិកានៃកម្មវិធីឡជីវឧស្ម័នជាតិ សម្រាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំ ៣ឆ្នាំ និងប្រចាំឆ្នាំ។

ឯកសារគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥ នឹងត្រូវពិនិត្យឡើងវិញក្នុងរយៈពេល៥ឆ្នាំម្តង ដោយមានការចូលរួមពីគ្រប់ភាគី និងមានការសម្របសម្រួលដោយគណៈកម្មាធិការប្រឹក្សាយោបល់ថ្នាក់ជាតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៦. ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ

ការត្រួតពិនិត្យតាមដាននិងវាយតម្លៃ គឺជាឧបករណ៍មួយដ៏សំខាន់ក្នុងការវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥។ ប្រព័ន្ធនៃការត្រួតពិនិត្យតាមដាននិងវាយតម្លៃ និងការសិក្សាដកស្រង់នូវបទពិសោធន៍នឹងត្រូវបានបង្កើត និងអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីពិនិត្យវាយតម្លៃនូវការសាយភាយនៃការកសាងនិងប្រើប្រាស់ឡជីវឧស្ម័ននៅកម្ពុជា។

ប្រព័ន្ធរាយការណ៍អំពីប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការប្រើប្រាស់ឡជីវឧស្ម័ន នឹងត្រូវបានកំណត់ច្បាស់លាស់ សំដៅតម្រង់ទិសអនុវត្តឱ្យស្របតាមការវិវឌ្ឍរីកចម្រើន នៃការអភិវឌ្ឍឡជីវឧស្ម័នជាសកល។ ការរាយការណ៍នឹងត្រូវបានរៀបចំជាប្រចាំឆ្នាំ រៀងរាល់៣ឆ្នាំ និងរាល់៥ឆ្នាំម្តង ដោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល។ មន្ទីរកសិកម្មរាជធានី ខេត្ត នឹងត្រូវចូលរួមសហការជាចាំបាច់ ក្នុងការវាយតម្លៃការអនុវត្តគោលនយោបាយនេះ។

នាយកដ្ឋានផែនការនិងស្ថិតិ នឹងមានតួនាទីយ៉ាងសំខាន់ ក្នុងការសម្របសម្រួល និងចូលរួមអនុវត្ត ការងារត្រួតពិនិត្យតាមដាននិងវាយតម្លៃ ដោយសហការយ៉ាងជិតស្និទ្ធ ជាមួយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងពិនិត្យលើរបាយការណ៍វាយតម្លៃទាំងនេះ និងត្រូវកែសម្រួលវិធានការគោលនយោបាយ ក្នុងករណីមានការស្នើកែប្រែកែលម្អគោលនយោបាយ។

## ៧. សេចក្តីសន្និដ្ឋាន

គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥ ដែលបានរៀបចំនេះ បានកំណត់យ៉ាងច្បាស់លាស់នូវចក្ខុវិស័យ ទិសដៅគោលនយោបាយយុទ្ធសាស្ត្រជាក់ស្តែង ក្នុងបេសកកម្មរយៈពេលមធ្យម និងវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលវិធានការគោលនយោបាយជាច្រើនត្រូវបានដាក់ចេញ និងមានការពាក់ព័ន្ធនៅក្នុងការអនុវត្តដល់ផ្នែកនានា ក្នុងគ្រប់អនុវិស័យទាំងអស់នៅក្រោមការគ្រប់គ្រងរបស់ក្រសួង និងទាមទារឲ្យមានការចូលរួមសហការអនុវត្តពីអង្គភាពពាក់ព័ន្ធ អង្គការជាតិនិងអន្តរជាតិ រួមទាំង វិស័យឯកជនផងដែរ ដើម្បីរួមចំណែកអនុវត្តគោលនយោបាយ ដែលបានដាក់ចេញ សំដៅជំរុញកំណើនវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមនិងជឿជាក់ថា រាជរដ្ឋាភិបាលកម្ពុជានឹងចាត់ទុកគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥ ជាអាទិភាពខ្ពស់ និងបន្តផ្តល់ការគាំទ្រខ្លាំងក្លាបន្ថែមទៀតដល់ការអនុវត្តគោលនយោបាយនេះ កាត់បន្ថយបាននូវឥទ្ធិពលអវិជ្ជមាននានាដែលអាចកើតមាន ធានាបាននូវកំណើនរីកលូតលាស់ក្នុងវិស័យកសិកម្ម ពិសេសអនុវិស័យចិញ្ចឹមសត្វប្រកបដោយចីរភាព ដើម្បីធ្វើជាកម្លាំងចលករជំរុញកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ពិសេសប្រជាកសិករនៅមូលដ្ឋានជនបទ ជាមួយនឹងការបង្កើនថវិកាវិនិយោគសាធារណៈព្រមទាំងបង្កើនការគៀងគរ ក៏ដូចជាការប្រើប្រាស់ធនធានជំនួយពីបរទេសឲ្យបានច្រើនជាងមុន សំដៅការអនុវត្ត និងជំរុញកំណើនផលិតកម្មសត្វ ការគ្រប់គ្រងកាកសំណល់ពីការចិញ្ចឹមសត្វ ប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមរយៈការអនុវត្តគោលនយោបាយនេះ។

គោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥ គឺពិតជាមានសារៈសំខាន់យ៉ាងខ្លាំងបំផុត និងបានរៀបចំឡើងស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨ ក្នុងការបង្ហាញឲ្យឃើញអំពីទិសដៅគោលនយោបាយមួយច្បាស់លាស់ និងបង្ហាញនូវគោលដៅអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលជាក់ស្តែងនាឆ្នាំ២០២៥ខាងមុខ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្តេជ្ញាចិត្តខ្ពស់ក្នុងការជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥នេះ ក្នុងគោលដៅចម្បងជំរុញការអភិវឌ្ឍអនុវិស័យផលិតកម្មសត្វកម្ពុជាប្រកបដោយប្រសិទ្ធភាព និងបង្កើនការគ្រប់គ្រងកាកសំណល់សត្វបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស អនាម័យល្អនៅមូលដ្ឋាន ហើយសង្ឃឹមថាសមិទ្ធផលក្រោមក្របខ័ណ្ឌគោលនយោបាយនេះ នឹងទទួលបានលទ្ធផលជាវិជ្ជមានជាក់ស្តែងចាប់ពីពេលនេះតទៅ។